នស/រកត/០២១៧/០៧៨

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនិង ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅផ្តល់ជូននូវតាវកាលិកសន្តិសុខសង្គម ផ្នែកហានិភ័យការងារចំពោះមន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពចំពោះមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ៖

១. មន្ត្រីសាធារណៈដូចខាងក្រោម៖

ក. មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ខ. មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

គ. មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ។
ឃ. មន្ត្រីនគរបាលជាតិ។
ង. មន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ។

២. អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន។

៣. មន្ត្រីសាធារណៈក្រៅពីចំណុច១ខាងលើនិងអ្នកនៅក្នុងបន្ទុកដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យដោយផ្អែកលើស្ថានភាពសង្គមនិងសេដ្ឋកិច្ចជាក់ស្តែង។

ចំពោះរបបសន្តិសុខសង្គមសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នឹងមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេស ដែលប្រើនៅក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សំដៅដល់ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ
- គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈដោយធ្វើការឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន
- គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈក្នុងពេលធ្វើដំណើរពីលំនៅឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការឬវិលមកវិញដោយគ្មានឈប់ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ក្រៅពីការងារដែលក្រសួង ស្ថាប័ន ឬអង្គភាពតម្រូវឱ្យទៅ
- ជំងឺវិជ្ជាជីវៈ សំដៅដល់ជំងឺនានាដែលកើតឡើងដោយមានមូលហេតុពីការងារឬពាក់ព័ន្ធនឹងការងារ ទោះជាជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ
- តាវកាលិកផ្នែកហានិភ័យការងារសំដៅដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ វិភាជន៍ ឬធនលាភបាត់បង់សមត្ថភាពការងារសម្រាប់ផ្តល់ជូនមន្ត្រីសាធារណៈដែលរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ និងធនលាភឧត្តរជីវីសម្រាប់ផ្តល់ជូនសិទ្ធិវន្តនៃជនរងគ្រោះ ដែលរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ បណ្តាលឱ្យបាត់បង់ជីវិត
- តាវកាលិកផ្នែកថែទាំសុខភាព សំដៅដល់សេវាបង្ការសុខភាពនិងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សម្រាប់ផ្តល់ជូនជនទាំងឡាយដូចមានចែងក្នុងមាត្រា៣ខាងលើ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- ភាគទាន សំដៅដល់ប្រាក់ដែលមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងរដ្ឋត្រូវបង់តាមច្បាប់ទុកជាមូលនិធិសម្រាប់ការផ្តល់តាវកាលិក
- អតីតមន្ត្រីរាជការ សំដៅដល់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ
- អតីតយុទ្ធជន សំដៅដល់និវត្តជន ជនពិការ និងជនបាត់បង់សមត្ថភាពការងារ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៦ .-**

សមាជិកក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមកពីផ្នែកសាធារណៈ ត្រូវមានសមត្ថកិច្ចក្នុងការប្រជុំពិភាក្សានិងអនុម័តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈនិងអតីតមន្ត្រីរាជការ អតីតយុទ្ធជនដោយមានការអញ្ជើញតំណាង បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស.) បេឡាជាតិអតីតយុទ្ធជន(ប.ជ.អ.) មូលនិធិជនពិការ(ម.ជ.ព.) និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់យោបល់។

សេចក្តីសម្រេចដែលក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម បានប្រជុំពិភាក្សា និងអនុម័ត ត្រូវសុំការពិនិត្យនិងយល់ព្រមពីក្រសួងអាណាព្យាបាលបច្ចេកទេសនិងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុង
## ផ្នែកទី១
## របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ

**មាត្រា៧ .-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ គឺជាបន្ទុករបស់រដ្ឋ ស្ថាប័ន ឬអង្គភាពគ្រប់គ្រងផ្ទាល់។

អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៨ .–**

តាវកាលិកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ មានដូចខាងក្រោម៖

- ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- ប្រាក់វិភាជសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០%
- ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%ឡើង
- វិភាជន៍បូជាសព ធនលាភឧត្តរជីវី សម្រាប់សហព័ទ្ធនិងកូន ព្រមទាំងជនចាស់ជរាពុំមានប្រាក់ចំណូលដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះដោយហានិភ័យការងាររហូតបាត់បង់ជីវិត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់ផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
## សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន

**មាត្រា៩ .–**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជាបន្ទុករួមគ្នារវាងរដ្ឋ ស្ថាប័ន ឬអង្គភាពគ្រប់គ្រងផ្ទាល់ ជាមួយនឹងមន្ត្រីសាធារណៈ។

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាបន្ទុកផ្ទាល់របស់សាមីខ្លួន។ អត្រាភាគទានដែលជាបន្ទុករបស់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មិនត្រូវលើសផ្នែកនៃភាគទានដែលជាបន្ទុករបស់មន្ត្រីសាធារណៈ។

អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ .–**

តាវកាលិកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានដូចខាងក្រោម៖

- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រដែលរួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសង្គ្រោះបន្ទាន់ សេវាព្យាបាលដោយស្តុំ និងដោយចលនា សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល និងសេវាស្តារនីតិសម្បទា
- សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ ចំពោះករណីសង្គ្រោះបន្ទាន់ និងសេវាបញ្ជូនសព សេវាបង្ការសុខភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកនៃផ្នែកនេះត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៣
## ប្រាក់ត្រៀមបម្រុង

**មាត្រា១១ .-**

ប្រាក់ត្រៀមបម្រុងនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលទាំងពីរ។

## ជំពូកទី៤
## ការទទួលស្គាល់និងការត្រួតពិនិត្យគុណភាពសេវា របស់មូលដ្ឋានសុខាភិបាល

**មាត្រា១២ .-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។

**មាត្រា១៣ .-**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងវាយតម្លៃដោយគណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម។

## ជំពូកទី៥
## កិច្ចសម្របសម្រួលផ្នែកគ្រប់គ្រងទិន្នន័យ

**មាត្រា១៤ .-**

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព។

## ជំពូកទី៦
## ការអនុវត្ត

**មាត្រា១៥ .-**

ដំណាក់កាលនិងកាលបរិច្ឆេទជាក់លាក់សម្រាប់ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១៧០២.០៩០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា**

**អ៊ិត សំហេង**

លេខ: ៩៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**